**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជធានីភ្នំពេញ**

**រដ្ឋបាលខណ្ឌដង្កោ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ អាស្ត្រាហ្សេនីកា (ដូសជំរុញ)ជូនប្រជាពលរដ្ឋ ដែលមានអាយុ៦០ឆ្នាំឡើងដែលបានចាក់វ៉ាក់សាំងអាស្ត្រាហ្សេនីកា-កូវីសែលលើកទី១ និងលើកទី២រួចរាល់ ចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១

**រដ្ឋបាលខណ្ឌដង្កោ** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បងប្អូនប្រជាពលរដ្ឋមានអាយុ៦០ឆ្នាំឡើង នៅក្នុងមូលដ្ឋានខណ្ឌដង្កោទាំងអស់ដែលបានចាក់វ៉ាក់សាំងការពារកូវីដ-១៩ អាស្ត្រាហ្សេនីកា នៅមន្ទីរពេទ្យបង្អែកដង្កោ មណ្ឌលសុខភាពព្រៃវែង និងមណ្ឌលសុខភាពជើងឯក មេត្តាជ្រាបថា យោងតាម "**គោលនយោបាយចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសជំរុញ**" ដែលបានដាក់ចេញដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងផែនការចាក់វ៉ាក់សាំងដូសជំរុញជូនប្រជាពលរដ្ឋដែលមានអាយុ៦០ឆ្នាំឡើង របស់សាលារាជធានីភ្នំពេញ សូមអញ្ជើញបងប្អូនប្រជាពលរដ្ឋមានអាយុ៦០ឆ្នាំឡើង មកទទួលចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ អាស្ត្រាហ្សេនីកា ដូសជំរុញ ដោយភ្ជាប់មកជាមួយអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងប័ណ្ណចាក់វ៉ាក់សាំងរួចរាល់ទាំងពីរលើក គិតចាប់ពីថ្ងៃទី០៦ ដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ នៅតាមទីតាំង និងកាលបរិច្ឆេទដូចខាងក្រោម៖

| ល.រ | ទីតាំងចាក់វ៉ាក់សាំង | កាលបរិច្ឆេទ | ផ្សេងៗ |
|---|---|---|---|
| ១ | មន្ទីរពេទ្យបង្អែកដង្កោ | ០៦-២០ កញ្ញា ២០២១ | |
| ២ | មណ្ឌលសុខភាពសាក់សំពៅ | | |
| ៣ | មណ្ឌលសុខភាពរលួស | | |
| ៤ | មណ្ឌលសុខភាពព្រែកកំពឹស | | |
| ៥ | មណ្ឌលសុខភាពពងទឹក | | |
| ៦ | មណ្ឌលសុខភាពព្រៃវែង | | |
| ៧ | មណ្ឌលសុខភាពព្រៃស | | |
| ៨ | មណ្ឌលសុខភាពជើងឯក | ០៩-២០ កញ្ញា ២០២១ | |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនប្រជាពលរដ្ឋដែលមានអាយុ៦០ឆ្នាំឡើង និងមិនទាន់បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសជំរុញ មេត្តាជ្រាបជាព័ត៌មាន ព្រមទាំងយកចិត្តទុកដាក់អនុវត្តវិធានការ "**៣ ការពារ ៣ កុំ**" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងវិធានការណែនាំនានារបស់ក្រសួងសុខាភិបាល ដើម្បីធានាបាននូវសណ្តាប់ធ្នាប់ របៀបរៀបរយ ជាពិសេសត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនដោយសហការជាមួយក្រុមការងារសម្របសម្រួលរដ្ឋបាលខណ្ឌ រក្សាគម្លាតសុវត្ថិភាព ពាក់ម៉ាស់ នៅតាមទីតាំងចាក់វ៉ាក់សាំង ដើម្បីទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ ។/.

ថ្ងៃ ១៤រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ភ្នំពេញ ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០២១

**រដ្ឋបាលខណ្ឌដង្កោ**